01104180

E329/9

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 06 / 2015
ម៉ោង (Time/Heure) : 14:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥

ជូនចំពោះ៖ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ
ភាគីទាំងអស់នៃសំណុំរឿង ០០២

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ៖ ដីកាបង្គាប់ឲ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស

១. នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ វេជ្ជបណ្ឌិត ហួត លីនណា និង វេជ្ជបណ្ឌិត CHAN Kin Ming ("អ្នកជំនាញ") បានដាក់ជូនរបាយការណ៍ស្តីពីសុខភាពផ្លូវចិត្ត និង ផ្លូវកាយរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន។ នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អង្គជំនុំជម្រះ និង ភាគី បានសួរដេញដោលអ្នកជំនាញអំពីសំអាងហេតុ និង មតិយោបល់របស់ពួកគេ នៅអំឡុងពេលសវនាការមួយ។ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយដោយបានបញ្ជាក់ថា ជនជាប់ចោទទាំងពីរនៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ (ឯកសារ E329/7; ឯកសារ E329/8)។ ដោយផ្អែកលើអនុសាសន៍របស់អ្នកជំនាញ អង្គជំនុំជម្រះបានសម្រេចកាត់បន្ថយរយៈពេលធ្វើសវនាការប្រចាំថ្ងៃ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៥ ទំព័រ ២២)។

២. ក្នុងពេលសវនាការនោះ វេជ្ជបណ្ឌិត ហួត លីនណា បានផ្តល់មតិយោបល់ថា អង្គជំនុំជម្រះគម្បីចាត់ឲ្យមានការធ្វើតេស្តទៅលើមុខងារនៃដំណើរការខួរក្បាលរបស់ជនជាប់ចោទនីមួយៗ

យ៉ាងហោចណាស់រៀងរាល់បីខែម្តង ដើម្បីទទួលបាននូវព័ត៌មានកាន់តែពេញលេញសម្រាប់ការពិនិត្យនៅពេលអនាគតទៅលើសម្បទារបស់ពួកគាត់ក្នុងការចូលរួមសវនាការ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៦-១៨)។ តេស្តដែលនឹងត្រូវអនុវត្ត ត្រូវតែផ្លាស់ប្តូរជាទៀងទាត់ ដើម្បីកុំឱ្យលទ្ធផលដែលនឹងទទួលបាន ទទួលរងនូវផលប៉ះពាល់ដោយសារភាពស៊ាំទៅនឹងតេស្តនោះ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣៤)។ អង្គភាពគាំពារសាក្សី និង អ្នកជំនាញបានចាប់ផ្តើមស្វែងរកវេជ្ជបណ្ឌិតដែលមានគុណវុឌ្ឍិ ដើម្បីអនុវត្តតេស្តទាំងនេះ ក្រោយពេលសវនាការបានបញ្ចប់។

៣. ដោយសារមានការលំបាកក្នុងការស្វែងរកវេជ្ជបណ្ឌិតក្នុងប្រទេស ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង និង ក្រោយពីមានការពិគ្រោះយោបល់បន្ថែមជាមួយអង្គភាពគាំពារសាក្សី និង អ្នកជំនាញនោះ ឥឡូវនេះ អ្នកជំនាញស្នើបង្កើតឡើងនូវតេស្តដោយអ្នកជំនាញផ្ទាល់ សម្រាប់អនុវត្តរៀងរាល់ត្រីមាស ហើយតេស្តនេះនឹងត្រូវយកទៅអនុវត្តដោយអង្គភាពពេទ្យនៃមន្ទីរឃុំឃាំង អ.វ.ត.ក ។ អ្នកជំនាញក៏ស្នើផងដែរថា ពួកគេនឹងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកមន្ទីរ ឃុំឃាំង អ.វ.ត.ក អំពីរបៀបអនុវត្តតេស្ត និង របៀបធ្វើរបាយការណ៍អំពីលទ្ធផលនៃការធ្វើតេស្តនីមួយៗ។

៤. ដោយពិចារណាឃើញថាតេស្តទាំងនេះមានគោលបំណងផ្តល់នូវព័ត៌មានកាន់តែលម្អិតទៅលើសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទដើម្បីការវាយតម្លៃទៅលើសម្បទាក្នុងការចូលរួមសវនាការនៅថ្ងៃអនាគត អង្គជំនុំជម្រះយល់ឃើញថា វេជ្ជបណ្ឌិត ហួត លីនណា និង វេជ្ជបណ្ឌិត CHAN Kin Ming គឺជាអ្នកជំនាញដែលមានគុណវុឌ្ឍិ និង មានសមត្ថភាពខ្ពស់បំផុតក្នុងការកំណត់ទៅលើទម្រង់នៃតេស្តដែលត្រូវអនុវត្ត (ឯកសារ E301/10 កថាខណ្ឌ ១០; ឯកសារ E329 លេខជើងទំព័រ ២៥) ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះចាត់តាំងវេជ្ជបណ្ឌិត ហួត លីនណា និង វេជ្ជបណ្ឌិត CHAN Kin Ming ឱ្យរៀបចំតេស្តនានាដើម្បីវាយតម្លៃទៅលើមុខងារនៃដំណើរការខួរក្បាលរបស់ជនជាប់ចោទ និង ធ្វើការជាមួយបុគ្គលិកមន្ទីរឃុំឃាំង អ.វ.ត.ក ដែលមានគុណវុឌ្ឍិក្នុងការគ្រប់គ្រង និង ធ្វើរបាយការណ៍អំពីលទ្ធផលនៃតេស្តទាំងនេះ។ អង្គជំនុំជម្រះបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ សម្របសម្រួល និង កំណត់វេលានៃការធ្វើតេស្តទាំងនេះ ដែលនឹងចាប់ផ្តើមមិនឱ្យហួសពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៥ ហើយត្រូវធ្វើតេស្តរៀងរាល់ត្រីមាសម្តង បន្ទាប់ពីតេស្តទីមួយត្រូវបានចាត់ចែងរួច។